**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រុមប្រឹក្សាសកម្មភាពជនពិការ**
លេខ:.០០១/១៣.ក.ស.ជ

រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ ២០១៣

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតគណៈកម្មាធិការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការ

*******

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
## និងជាប្រធានក្រុមប្រឹក្សាសកម្មភាពជនពិការ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៩/០០១ ចុះថ្ងៃទី ០៣ ខែកក្កដា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ២០១០ ស្តីពីការរៀបចំសមាសភាព និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាសកម្មភាពជនពិការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩១២/០០៧ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជា ចូលជាភាគីនៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ។

## សម្រេច

**ប្រការ ១ .-**

ត្រូវបានបង្កើត គណៈកម្មាធិការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការ មានអក្សរកាត់ថា **គ.អ.ស.ព** ភាសាអង់គ្លេស Committee for the Implementation of the Convention on the Rights for Person with Disability មានអក្សរកាត់ថា CIRPD ជាយន្តការ និងជាគណៈកម្មាធិការជំនាញអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការ។

**ប្រការ ២ .-**

គណៈកម្មាធិការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១. ឯកឧត្តម | **អ៊ិត សំហេង** | រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងជាប្រធានក្រុមប្រឹក្សាសកម្មភាពជនពិការ | ប្រធាន |
| ២. ឯកឧត្តម | **សែម សុខា** | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | អនុប្រធាន |
| ៣. ឯកឧត្តម | **សេង លឹមនៅ** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៤. ឯកឧត្តម | **តែ គុយស៊ាង** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | អនុប្រធាន |
| ៥. ឯកឧត្តម | **តេង សាវង្ស** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៦. ឯកឧត្តម | **នាង ផាត** | រដ្ឋលេខាធិការក្រសួងការពារជាតិ | អនុប្រធាន |
| ៧. ឯកឧត្តម | **ឃី ខាសនា** | ទីប្រឹក្សារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងជានាយកប្រតិបត្តិមជ្ឈមណ្ឌលជាតិនៃជនពិការ | អនុប្រធាន |
| ៨. ឯកឧត្តម | **ចាន់ រដ្ឋា** | អគ្គលេខាធិការរងទទួលបន្ទុកកិច្ចសង្គ្រោះជនពិការ ដោយសារមីននៃអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាព កំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន | សមាជិក |
| ៩. ឯកឧត្តម | **គុយម៉ារិនឌី** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១០. ឯកឧត្តម | **ជា អឿង** | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១១. ឯកឧត្តម | **ហាប់ អូម៉ាលី** | អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១២. ឯកឧត្តម | **រិន ធីរៈ** | អនុរដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ១៣. ឯកឧត្តម | **ហ៊ុយ សារ៉ាវុធ** | អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| ១៤. ឯកឧត្តម | **មាស ម៉ូនីកា** | អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១៥. លោកជំទាវ | **ចិត្យ ច័ន្ទតារីន** | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១៦. លោកជំទាវ | **ញ៉ៀម មរកត** | អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី | សមាជិក |
| ១៧. ឯកឧត្តម | **ចាប ឫទ្ធី** | អនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៨. ឯកឧត្តម | **ពៅ ស៊ីង** | អនុរដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១៩. ឯកឧត្តម | **ម៊ុន ខេង** | អនុរដ្ឋលេខាធិការ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | សមាជិក |
| ២០. លោកជំទាវ | **ម៉ែន នារីសោភ័គ** | អគ្គលេខាធិការរងកាកបាទក្រហមកម្ពុជា | សមាជិក |
| ២១. ឯកឧត្តម | **រិត វុទ្ធី** | អគ្គលេខាធិការរង គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ២២. ឯកឧត្តម | **សាន វឌ្ឍនា** | អគ្គលេខាធិការរង ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍ វិស័យកសិកម្ម និងជនបទ | សមាជិក |
| ២៣. ឯកឧត្តម | **ឌួន ម៉េងតិច** | អគ្គនាយកសភាពាណិជ្ជកម្មកម្ពុជា | សមាជិក |
| ២៤. លោក | **ចិន សៅរ័ត្ន** | នាយកប្រតិបត្តិអង្គការជនពិការកម្ពុជា | សមាជិក |
| ២៥. លោក | **មួន ម៉ៅ** | នាយកប្រតិបត្តិសមាគមជនពិការភ្នែកកម្ពុជា | សមាជិក |
| ២៦. កញ្ញា | **សុខ កុសល** | តំណាងអង្គការ Jesuit Service Cambodia | សមាជិក |
| ២៧. កញ្ញា | **ស្រេង វណ្ណី** | តំណាងអង្គការគ្រួសារថ្មី | សមាជិក |
| ២៨. លោក | BENJAMIN NGUYEN | នាយកអង្គការជនពិការអន្តរជាតិ | សមាជិក |
| ២៩. លោក | **ជូរ រតនៈ** | នាយកមូលនិធិជនពិការ | សមាជិក |
| ៣០. លោក | **ឡៅ វ៉េង** | ប្រធាននាយកដ្ឋានសុខុមាលភាពជនពិការ | សមាជិក |
| ៣១. លោក | **ឯម ច័ន្ទមករា** | លេខាធិការនៃ ក.ស.ជ | សមាជិកអចិន្ត្រៃយ៍ |

**ប្រការ ៣ .-**

គណៈកម្មាធិការនេះមានសិទ្ធិប្រើប្រាស់ត្រាក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ គណៈកម្មាធិការអាចបង្កើតអនុគណៈកម្មាធិការរបស់ខ្លួនមួយចំនួនតាមការចាំបាច់។

**ប្រការ ៤ .-**

ត្រូវបានប្រគល់ភារកិច្ចជូនលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ ជាលេខាធិការដ្ឋាននៃគណៈកម្មាធិការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការ ក្នុងការអនុវត្តភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។

**ប្រការ ៥ .-**

គណៈកម្មាធិការនេះមានភារកិច្ចដូចខាងក្រោម៖

- បង្កើតអនុគណៈកម្មការ ឬ ក្រុមការងារជំនាញដែលធ្វើការលើអនុសញ្ញាស្តីពីសិទ្ធិជនពិការ
- រៀបចំផែនការសកម្មភាពស្តីពី ការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការឲ្យមានប្រសិទ្ធភាព
- ពិនិត្យ តាមដាន និងវាយតម្លៃវឌ្ឍនភាពនៃការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការ
- សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំរបាយការណ៍ស្តីពី ការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការ
- បំពេញកាតព្វកិច្ចក្នុងការជួយរាជរដ្ឋាភិបាល ដើម្បីរាយការណ៍ជូនអង្គការសហប្រជាជាតិស្តីពីលទ្ធផលនៃការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការក្នុងនាមជារដ្ឋភាគី
- រៀបចំវគ្គបណ្តុះបណ្តាលស្តីពីអនុសញ្ញាសិទ្ធិជនពិការដល់អ្នកពាក់ព័ន្ធនៅទូទាំងប្រទេស
- រៀបចំការផ្សព្វផ្សាយស្តីពីអនុសញ្ញាសិទ្ធិជនពិការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- រៀបចំកិច្ចប្រជុំ និងព្រឹត្តិការណ៍ផ្សេងៗជាមួយអន្តរក្រសួង ស្ថាប័ន អង្គការពាក់ព័ន្ធលើការងារដែលពាក់ព័ន្ធអនុសញ្ញាស្តីពីសិទ្ធិជនពិការ
- កៀរគរប្រភពធនធាន ទាំងថវិកា និងបច្ចេកទេស ក្នុងការជំរុញការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការឲ្យមានប្រសិទ្ធភាព
- សម្របសម្រួល និងរៀបចំដំណើរការក្នុងផ្តល់សច្ចាប័នទៅលើពិធីសារបន្ថែមនៅពេលខាងមុខ
- អនុវត្តការងារផ្សេងៗទៀតតាមការណែនាំពីប្រធាន ក.ស.ជ

**ប្រការ ៦ .-**

សមាជិកគណៈកម្មាធិការ ក្រុមប្រឹក្សាសកម្មភាពជនពិការ គ្រប់អង្គភាព ក្រោមឱវាទក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គ្រប់ក្រសួង ស្ថាប័ន និងផ្នែកពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**
**និងជាប្រធានក្រុមប្រឹក្សាសកម្មភាពជនពិការ**

**វ៉ុង សំហេង**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម-លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ដូចប្រការ ៦
- ឯកសារ – កាលប្បវត្តិ